**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានសង្គមកិច្ច និងយុវនីតិសម្បទា

※※※※※※※

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩ /០៦ ចុះថ្ងៃទី ១៧ ខែ មិថុនាឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

## ស ម្រេ ច

**មាត្រា១.-**

ត្រូវបានកែសម្រួលរចនាសម្ព័ន្ធ និង ភារកិច្ចអង្គភាពមួយចំនួន របស់អគ្គនាយកដ្ឋានសង្គមកិច្ច និង យុវនីតិសម្បទា នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ។

**មាត្រា២.-**

**អគ្គនាយកដ្ឋានសង្គមកិច្ច និងយុវនីតិសម្បទា** មានភារកិច្ចធ្វើជាសេនាធិការឱ្យក្រសួងលើការងារ ធ្វើទំនាក់ទំនង សំរបសំរួល គ្រប់គ្រងកិច្ចការសុខុមាលភាពសង្គម សុខុមាលភាពកុមារ ស្តារលទ្ធភាពពលកម្ម និងការងារយុវនីតិសម្បទា ។

អគ្គនាយកដ្ឋានសង្គមកិច្ច និងយុវនីតិសម្បទា ដឹកនាំដោយអគ្គនាយកមួយរូប និង មានអគ្គនាយករងមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

អគ្គនាយកដ្ឋានសង្គមកិច្ច និងយុវនីតិសម្បទា មាននាយកដ្ឋាន ៥ គឺ :

១- នាយកដ្ឋាន សុខុមាលភាពសង្គម

២- នាយកដ្ឋាន សោធននិវត្តន៍

៣- នាយកដ្ឋាន សុខុមាលភាពកុមារ

៤- នាយកដ្ឋាន ស្តារលទ្ធភាពពលកម្ម

៥- នាយកដ្ឋាន យុវនីតិសម្បទា ។

**មាត្រា៣.-**

**នាយកដ្ឋានសុខុមាលភាពសង្គម** មានភារកិច្ច :

-កសាងគោលនយោបាយ ច្បាប់ និង បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងការងារសុខុមាលភាពសង្គម

-ជួយដល់ក្រុមជនដែលជួបការលំបាកជាងគេនៅក្នុងសង្គម ជនក្រីក្រគ្មានទីពឹង ជនចាស់ជរាគ្មានទីពឹង និងជនរស់នៅតាមចិញ្ចើមថ្នល់

-សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ចាត់វិធានការទប់ស្កាត់អំពើពេស្យាចារ ការជួញដូរមនុស្ស និងអនុវត្តកម្មវិធីសង្គ្រោះជនរងគ្រោះ អប់រំបណ្តុះបណ្តាល និង ធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញ

-ជួយជនរងគ្រោះដោយមហន្តរាយផ្សេងៗ មានគ្រោះថ្នាក់ធម្មជាតិ សង្គ្រាម និង គ្រោះថ្នាក់ផ្សេងៗទៀត

-សហការត្រួតពិនិត្យ និង វាយតម្លៃលទ្ធផលអនុវត្តកម្មវិធី គំរោងរបស់អង្គការក្រៅរដ្ឋាភិបាលដែលបានចុះអនុស្សរណៈជាមួយក្រសួងលើការងារសុខុមាលភាពសង្គម

-តាមដានត្រួតពិនិត្យ វាយតម្លៃការអនុវត្តន៍គោលការណ៍ គោលនយោបាយ នៅថ្នាក់មូលដ្ឋានខេត្ត ក្រុងលើការងារសុខុមាលភាពសង្គម

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានសុខុមាលភាពសង្គម ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

មាត្រា៤.-

**នាយកដ្ឋានសោធននិវត្តន៍** មានភារកិច្ច :

-កសាងគោលនយោបាយ ច្បាប់ និង បទប្បញ្ញត្តិនានា ពាក់ព័ន្ធទៅនឹងការអនុវត្តន៍របបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ និង របបធានារ៉ាប់រងសង្គមចំពោះមន្ត្រីរាជការស៊ីវិល

-គ្រប់គ្រងរបបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ សំរាប់មន្ត្រីរាជការតាមការកំណត់នៃច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-គ្រប់គ្រងរបបធានារ៉ាប់រងសង្គម ដល់កូនសពមន្ត្រីរាជការ កូនជនមរណៈនៃនគរបាលជាតិ និងគ្រួសារសព និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ

-តាមដានត្រួតពិនិត្យ វាយតម្លៃការអនុវត្តន៍គោលការណ៍ គោលនយោបាយនៅថ្នាក់មូលដ្ឋានខេត្ត ក្រុង លើការងារសោធននិវត្តន៍ សោធនបាត់បង់សម្បទាវិជ្ជាជីវៈ និង របបធានារ៉ាប់រងសង្គម

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានសោធននិវត្តន៍ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

មាត្រា៥.-

**នាយកដ្ឋានសុខុមាលភាពកុមារ** មានភារកិច្ច :

-ជួយដល់កុមារកំព្រា ដោយថែរក្សា ការពារ និងអប់រំគេអោយក្លាយជាពលរដ្ឋល្អក្នុងសង្គម

-រៀបចំគ្រប់គ្រងមណ្ឌលកុមារកំព្រា មណ្ឌលសង្គ្រោះទារកដែលគេបោះបង់ចោល

-សង្គ្រោះកុមារដែលគេរំលោភបំពានរាងកាយ ជួញដូរ និងធ្វើអាជីវកម្មខាងផ្លូវភេទ

-គ្រប់គ្រងការងារសុំកូនយកទៅចិញ្ចឹមនៅក្នុងប្រទេសនិងទៅបរទេសដោយសហការជាមួយក្រសួងពាក់ព័ន្ធ

-អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលចំពោះកុមារ តាមអនុសញ្ញា សន្ធិសញ្ញាអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជា ជាសមាជិក

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានសុខុមាលភាពកុមារ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

មាត្រា៦.-

**នាយកដ្ឋានស្តារលទ្ធភាពពលកម្ម** មានភារកិច្ច :

4r

-គ្រប់គ្រងការងារស្តារលទ្ធភាពពលកម្ម និង ការធ្វើសមាហរណកម្មទៅក្នុងសង្គមជាតិនៃជនពិការ

-ផ្តល់ការព្យាបាលដោយចលនាដល់ជនពិការគ្រប់ប្រភេទ

-គ្រប់គ្រងការផលិត និងការបំពាក់ឧបករណ៍ទ្រទ្រង់រាងកាយ ដល់ជនពិការ

-អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនពិការ

-ដោះស្រាយមុខរបរ និង អភិវឌ្ឍន៍ជីវភាពជនពិការតាមសហគមន៍

-រៀបចំតាក់តែង និង អនុវត្តគោលនយោបាយ ច្បាប់របស់រដ្ឋស្តីពីជនពិការ

-រៀបចំ និង ចាត់ចែងសកម្មភាពវប្បធម៌ សិល្បៈ និង កីឡាជនពិការកម្ពុជា

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានស្តារលទ្ធភាពពលកម្ម ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា៧.-**

**នាយកដ្ឋានយុវនីតិសម្បទា** មានភារកិច្ច :

-កសាងគោលនយោបាយ ច្បាប់ បទប្បញ្ញត្តិ ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងយុវនីតិសម្បទា

-សហការជាមួយស្ថាប័នពាក់ព័ន្ធ រិះរកវិធានការ និងផែនការទប់ស្កាត់អំពើពាល អនាថា អំពើល្មើសច្បាប់ ការសេពគ្រឿងញៀនរបស់កុមារ យុវកុមារ

-រៀបចំបង្កើតមជ្ឈមណ្ឌលអប់រំកុមារ យុវកុមារ ដែលមានអាយុក្រោម ១៨ ឆ្នាំ ដែលមានបញ្ហានៅតាមភូមិភាគ ខេត្ត ក្រុង ស្របទៅតាមអត្រាកំណើននៃបទល្មើសរបស់កុមារ យុវកុមារ

-សហការជាមួយក្រសួងមហាផ្ទៃ ដើម្បីរៀបចំអប់រំ និង បណ្តុះបណ្តាលវិជ្ជាជីវៈ សំរាប់ទណ្ឌិតនៅតាមពន្ធនាគារ

-សហការជាមួយស្ថាប័នពាក់ព័ន្ធ រិះរកវិធានការស្តារនីតិសម្បទាជនរងគ្រោះដោយគ្រឿងញៀន

-សហការត្រួតពិនិត្យ វាយតម្លៃលទ្ធផលអនុវត្តកម្មវិធី គំរោង របស់អង្គការក្រៅរដ្ឋាភិបាលដែលបានចុះអនុស្សរណៈជាមួយក្រសួង

-តាមដានត្រួតពិនិត្យ វាយតម្លៃលើការអនុវត្តន៍គោលការណ៍គោលនយោបាយថ្នាក់មូលដ្ឋានខេត្ត ក្រុង លើការងារយុវនីតិសម្បទា

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានយុវនីតិសម្បទា ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និង មានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

ux

**មាត្រា៨.-**

មាត្រា១២ មាត្រា១៣ មាត្រា១៤ មាត្រា១៥ មាត្រា១៦ និងមាត្រា១៧ ជំពូកទី៦អំពីអគ្គនាយកដ្ឋានសង្គមកិច្ច និងយុវនីតិសម្បទា នៃអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា**

**អ៊ិត សំហេង**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៩
-រាជកិច្ច
-កាលប្បវត្តិ - ឯកសារ